ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការស្នើសុំលិខិតអនុញ្ញាតនាំចូលគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍និង គ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍ និងការស្នើសុំវិញ្ញាបនបត្រទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍

និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) សូមជម្រាបជូនបណ្តាក្រុមហ៊ុន និងប្រតិបត្តិករទូរគមនាគមន៍ដែលកំពុងប្រតិបត្តិធុរកិច្ចនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍ទាំងអស់ថា ដើម្បីធានាប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ន.ទ.ក. បានរៀបចំនិងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងការស្នើសុំលិខិតអនុញ្ញាតនាំចូលគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍ និងការស្នើសុំវិញ្ញាបនបត្រទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍និងគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍។ ប្រព័ន្ធនេះ នឹងផ្តល់ភាពងាយស្រួល និងឆាប់រហ័ស ដល់ក្រុមហ៊ុន ឬប្រតិបត្តិករទូរគមនាគមន៍ ក្នុងការស្នើសុំលិខិតអនុញ្ញាតនិងវិញ្ញាបនបត្រខាងលើ។

ក្រុមហ៊ុន ឬប្រតិបត្តិករទូរគមនាគមន៍ដែលមានបំណងស្នើសុំសេវាទាំងពីរនេះ អាចចាប់ផ្តើមដាក់ពាក្យតាមរយៈគេហទំព័រ service.trc.gov.kh ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងទៅកាន់ ន.ទ.ក. ដែលមានអាសយដ្ឋាន ផ្លូវលេខ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬតាមរយៈលេខទូរស័ព្ទ ៦៧៨៩ នៅរៀងរាល់ម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូមបណ្តាក្រុមហ៊ុន ឬប្រតិបត្តិករទូរគមនាគមន៍ដែលប្រតិបត្តិការនាំចូល ផ្គត់ផ្គង់ និងចែកចាយគ្រឿងសម្ភារបរិក្ខារវិទ្យុគមនាគមន៍និងទូរគមនាគមន៍ជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤